## សិទ្ធិនិងការទទួលខុសត្រូវរបស់លោកអ្នក

# Your rights and responsibilities - Khmer

ឯកសារនេះនេះពន្យល់នូវអ្វីដែលលោកអ្នករំពឹងថានឹងទទួលកិច្ចបំរើពីយើង និង អ្វីដែលយើងរំពឹងថានឹងទទួលពីលោកអ្នកវិញ នៅពេលលោកអ្នកប្រើប្រាស់សេវាកម្មរបស់យើង។

### អ្វីដែលលោកអ្នកអាចរំពឹងថានឹងទទួលបានពីយើង

**ការគោរព**

- លោកអ្នកមានសិទ្ធិទទួលការប្រព្រឹត្តិចំពោះលោកអ្នកប្រកបដោយការគោរព និង សេចក្តីថ្លៃថ្នូរ។
- លោកអ្នកមានសិទ្ធិសួរនាំយើងដើម្បីផ្តល់នូវការថែរទាំដែលជួយបំពេញសេចក្តីត្រូវការចាំបាច់នានាខាងវប្បធ៌មនិងសាសនា។

យើងនឹងព្យាយាមបំពេញសេចក្តីត្រូវការចាំបាច់របស់លោកអ្នក  ហើយប្រសិនបើយើងមិនអាច យើងនឹងពន្យល់ទៅអ្នកអំពីមូលហេតុ។

**ការប្រាស្រ័យនិយាយទាក់ទង**

- លោកអ្នកមានសិទ្ធិទទួលពត៌មានស្តីអំពីកិច្ចបំរើ ការព្យាបាលថែរទាំសុខភាព ការជ្រើសរើសនៃការមើលថែរទាំ និង សោហ៊ុយក្នុងរបៀបមួយ ច្បាស់លាស់និងមានតម្លាភាព។
- លោកអ្នកមានសិទ្ធិសាកសួរសំណួរនៅពេលណាក៏បាន។
- លោកអ្នកអាចសុំស្នើអ្នកបកប្រែភាសាបានប្រសិនបើលោកអ្នកត្រូវការ។
- យើងនឹងខំប្រឹងប្រែងអោយអស់ពីលទ្ធភាពដើម្បីផ្តល់ពត៌មានជូនលោកអ្នកក្នុងរបៀបមួយងាយយល់។

**ការចូលរួមចំណែក**

- លោកអ្នកមានសិទ្ធិចូលរួមចំណែកក្នុងការសំរេចចិត្ត និងជ្រើសរើសនូវការថែរទាំសុខភាពរបស់លោកអ្នក។ ឧទាហរណ៍លោកអ្នកមានសិទ្ធិ ឲ្យក្រុមគ្រួសារ មិត្តភ័ក្របូអ្នកដែលជួយគាំទ្រលោកអ្នកក្នុងការធ្វើសេចក្តីសំរេចចិត្តស្តីអំពីការមើលថែរទាំរបស់លោកអ្នក។
- ក្នុងស្ថានភាពភាគច្រើនបំផុតលោកអ្នកអាចបដិសេធការថែរទាំបាន ប្រសិនបើលោកអ្នកមិនចង់ទទួលយកកិច្ចបំរើនោះ។
- លោកអ្នកមានសិទ្ធិចូលរួមចំណែកក្នុងកម្មវិធីស្រាវជ្រាវខ្លះរបស់យើង ឬក្នុងកម្មសិក្សារបស់និស្សិត។យើងនឹងសួរលោកអ្នកអំពីការណ៍នេះ ហើយបើលោកអ្នកមិនចង់ចូលរួមចំណែកលោកអ្នកក៏ពុំចាំបាច់ធ្វើដែរ។

**សុវត្ថិភាព**

- លោកអ្នកមានសិទ្ធិដើម្បីមានសុវត្ថិភាពក្នុងខណៈដែលលោកអ្នកកំពុងទទួលការមើលថែរទាំ។យើងនឹងធ្វើឲ្យប្រាកដថាគ្រប់ ការព្យាបាលថែរទាំ និងន្លែងសម្ភារៈបរិក្ខាទាំងអស់មានអនាម័យស្អាតនិងសុវត្ថិភាព។

**ការទទួលបានកិច្ចបំរើ**

- លោកអ្នកមានសិទ្ធិទទួលនូវការមើលថែរទាំសុខភាពប្រកបដោយគុណភាពខ្ពស់។
- យើងផ្តល់នូវការមើលថែរទាំផាលក្ខណៈសាធារណៈនិងឯកជន។ការមើលថែរទាំផាលក្ខណៈសាធារណៈ រដ្ឋាភិបាលជាអ្នកបង់ប្រាក់។ ប្រសិនបើលោកអ្នកមានការធានារ៉ាប់រងសុខភាពឯកជន លោកអ្នកមានសិទ្ធជ្រើសរើសការមើលថែរទាំផាលក្ខណៈឯកជនបាន។

**សិទ្ធិឯកជន**

- លោកអ្នកមានសិទ្ធិទទួលនូវភាពផាឯកជន  រួមមានការរក្សាការសំងាត់នៃពត៌មានស្តីអំពីសុខភាពរបស់លោកអ្នក។

**មតិយោបល់**

- លោកអ្នកមានសិទ្ធិបញ្ចេញមតិទៅលើការថែរទាំសុខភាពរបស់លោកអ្នក។យើងនឹងឆ្លើយតបទៅនឹងកង្វល់ណាមួយដែលលោកអ្នកមាន។

ប្រសិនបើលោកអ្នកត្រូវការអ្នកបកប្រែភាសា  សូមប្រាប់ឱ្យយើងដឹង៖ **131 450**

## អ្វីយើងរំពឹងថានឹងទទួលបានពីលោកអ្នកវិញ

MonashHealth

**ការគោរព**

- យើងរំពឹងថាលោកអ្នកនឹងប្រព្រឹត្តមកលើបុគ្គលិក អ្នកថែរទាំ ក្រុមគ្រួសារ និងភ្ញៀវរបស់យើងប្រកបដោយការគោរព និងសេចក្តីថ្លៃថ្នូរ។

**ការប្រាស្រ័យនិយាយទាក់ទង**

- សូមមេត្តាប្រាប់យើងឲ្យអស់នូវអ្វីៗដែលលោកអ្នកដឹងអំពីសុខភាពរបស់លោកអ្នក។ការណ៍នេះអាចរាប់បញ្ចូលទាំង៖
  - ប្រវត្តន៍វេជ្ជសាស្រ្តរបស់លោកអ្នក
  - ថ្នាំណាមួយក៏ដោយដែលលោកអ្នកកំពុងប្រើប្រាស់
  - ពិធិព្យាបាលគួបផ្សំ
  - ការគាំទ្រពីក្រុមគ្រួសារនិងសង្គម
  - អ្នកមានអារម្មណ៍ក្នុងខ្លួនអ្នកយ៉ាងណា
  - ជំនឿលើបែបផែនរស់នៅនិងវប្បធ៌ម
  - ប្រសិនបើលោកអ្នកមិនអាចនិយាយសំរាប់ខ្លួនឯងបាន លោកអ្នកអាចសុំឲ្យអ្នកផ្សេងជួយលោកអ្នកក៏បាន។

**ការចូលរួមចំណែក**

- សូមមេត្តាចូលរួមចំណែក្នុងការព្យាបាលថែរទាំរបស់លោកអ្នក។ការណ៍នេះមានន័យថា សួរសំណួរនិងធ្វើការជ្រើសរើសអំពីការព្យាបាល នឹងការមើលថែរទាំរបស់លោកអ្នក។

**សុវត្ថិភាព**

- យើងរំពឹងថាអ្នកនឹងប្រព្រឹត្តទៅលើទីកន្លែងសម្ភារ:បរិក្ខារបស់យើងប្រកបដោយការថែរទាំនិងរក្សាវាឲ្យបានស្អាតនិងមានសុវត្ថភាព។
  យើងសុំឲ្យលោកអ្នកធ្វើតាមវិធាននិងការណែនាំ។យើងសុំឲ្យលោកអ្នកកុំជក់បារីខណ:ដែលលោកអ្នកនៅកន្លែងសម្ភារ:បរិក្ខារបស់យើង។

**សិទ្ធិឯកជន**

- យើងរំពឹងថាលោកអ្នកនឹងគោរពសិទ្ធិឯកជនរបស់អ្នកដ៏ទៃ។

**តើអ្នកមានកង្វល់ណាមួយទេ?**

យើងចង់មានឳកាសដោះស្រាយកង្វល់ណាមួយដែលលោកអ្នកអាចមានឱ្យបានឆាប់តាមតែអាចធ្វើទៅបាន។ ប្រសិនបើលោកអ្នកមិនពេញចិត្តជាមួយបទពិសោធន៍របស់លោកអ្នកនៅម៉ូណាស្សហែល្ស(Monash Health)សូមនិយាយមកកាន់យើង៖

**ជំហ៊ានទី1៖**ចូរនិយាយទៅកាន់បុគ្គលិកដែលមើលថែរលោកអ្នក

**ជំហ៊ានទី2៖**ចូរសុំនិយាយជាមួយគិលានុប្បដ្ឋាយិកាដែលទទួលខុសត្រូវ

**ជំហ៊ានទី3៖**ប្រសិនបើកង្វល់របស់លោកអ្នកមិនទាន់បានដោះស្រាយឬប្រសិនបើលោកអ្នកមិនមានអារម្មណ៍ល្អនិយាយទៅកាន់ បុគ្គលិកប្រចាំការ លោកអ្នកអាចទាក់ទងនាយិកាទំនាក់ទំនងអតិថិជនរបស់យើង(Consumer Liaison Officers)៖

| | | | |
|---|---|---|---|
| Monash Medical Centre | **9594 2702** | Casey Hospital | **8768 1465** |
| Monash Children's Hospital | **9594 2702** | Cranbourne Centre | **8768 1465** |
| Dandenong Hospital | **9554 8078** | Mental Health | **9554 9237** |
| Moorabbin Hospital | **9928 8584** | Monash Health Community | **9554 9376** |
| Kingston Centre | **9265 100** | | |

ជម្រើសផ្សេងទៀតអ្នកអាចចូលមើលវិបសៃរបស់យើងនិងប្តល់មតិឱ្យយើង៖

www.monashhealth.org

ឬសរសេរមកកាន់យើង៖

Complaints and Compliments

Monash Health Locked Bag 29

Clayton South VIC 3169

ប្រសិនបើយើងមិនអាចដោះស្រាយកង្វល់របស់អ្នកបាន អ្នកអាចទាក់ទងស្នងការបណ្តឹងសុខាភិបាល(Health Complaints Commissioner)៖

Level 26, 570 Bourke Street

Melbourne VIC 3000

Telephone: **1300 582 113**

Website: **www.hcc.vic.gov.au**

**តម្លៃរបស់យើង៖ សុចរិតភាព សេចក្តីមេត្តា គណនេយ្យភាព ការគោរព ឧត្តមភាព**

ប្រសិនបើលោកអ្នកត្រូវការអ្នកបកប្រែភាសា សូមប្រាប់ឱ្យយើងដឹង៖ **131 450**